**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..២៣៩..អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតមូលនិធិបរិស្ថាននិងសង្គម

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើដោយច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញ អនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងបង្កើត "មូលនិធិបរិស្ថាននិងសង្គម" ដែលសរសេរជាអក្សរកាត់ថា "ម.ប.ស." ដែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រង ចាត់ចែង និងការទទួលខុសត្រូវរបស់ "គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម" ដែលសរសេរជាអក្សរកាត់ថា "គ.ម.ប.ស."។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែង "មូលនិធិបរិស្ថាននិងសង្គម" ឱ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដើម្បីស្តារបរិស្ថានឡើងវិញ គាំពារបរិស្ថាន អភិរក្សជីវៈចម្រុះ និងប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប មាននិរន្តរភាព និងការរស់នៅដោយចីរភាពសម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើសកម្មភាពទាក់ទងនឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម។

## ជំពូកទី២
## ការគ្រប់គ្រងមូលនិធិបរិស្ថាននិងសង្គម

**មាត្រា៤.-**

មូលនិធិបរិស្ថាននិងសង្គម ស្ថិតនៅក្រោមការគ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវដោយគណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម ដែលមានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រី ឬថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងបរិស្ថាន | ១រូប | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | អនុប្រធាន |
| - តំណាងក្រសួងបរិស្ថាន | ១រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានគាំពារបរិស្ថាន | ១រូប | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥.-**

គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- កំណត់នូវគោលនយោបាយនិងយុទ្ធសាស្ត្រប្រមូល គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់មូលនិធិ

បរិស្ថាននិងសង្គម

- ជំរុញម្ចាស់គម្រោងឱ្យបង់មូលនិធិបរិស្ថាននិងសង្គម
- ចាត់វិធានការរដ្ឋបាលនិងផ្លូវច្បាប់ ក្នុងការប្រមូលមូលនិធិបរិស្ថាននិងសង្គមពីម្ចាស់គម្រោង ដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន
- ធ្វើការសម្របសម្រួលជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន និងសប្បុរសជន ក្នុងការកៀរគរមូលនិធិបរិស្ថាននិងសង្គម
- ពិនិត្យ និងសម្រេចលើគម្រោងចំណូល ចំណាយរបស់មូលនិធិសម្រាប់បម្រើឱ្យការស្តារបរិស្ថានឡើងវិញ ការគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របមាននិរន្តរភាព និងការរស់នៅដោយចីរភាព
- គ្រប់គ្រង ប្រើប្រាស់ និងបែងចែកមូលនិធិដែលទទួលបានពីគម្រោងអភិវឌ្ឍន៍ឯកជន និងសាធារណៈ
- ពិនិត្យសម្រេចសំណើសុំប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម សម្រាប់បម្រើដល់វិស័យបរិស្ថាន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម ដែលបានផ្តល់ឱ្យ
- ធ្វើការណែនាំបច្ចេកទេសលើការគ្រប់គ្រង និងការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម សម្រាប់គម្រោងបម្រើវិស័យបរិស្ថាន
- ធ្វើរបាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍វឌ្ឍនភាពរបស់មូលនិធិបរិស្ថាននិងសង្គមរៀងរាល់ត្រីមាស ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៦.-**

គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម មានលេខាធិការដ្ឋាននៅអគ្គនាយកដ្ឋានគាំពារបរិស្ថាន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា៧.-**

គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម ប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថានសម្រាប់ដំណើរការការងារ។

## ជំពូកទី៣
## ប្រភពចំណូលនិងការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម

**មាត្រា៨.-**

ម.ប.ស មានប្រភពចំណូលមកពី៖

- បុព្វលាភពីម្ចាស់គម្រោងអភិវឌ្ឍន៍ឯកជននិងសាធារណៈ ដែលមានចែងនៅក្នុងផែនការគ្រប់គ្រង

បរិស្ថាននៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន

- ប្រាក់ចំណូលពីកិច្ចគាំពារបរិស្ថាន សេវាប្រព័ន្ធអេកូឡូស៊ីនិងអភិរក្សជីវៈចម្រុះ
- អំណោយ ឬជំនួយថវិកា សម្ភារៈ ឧបករណ៍នានាពីសប្បុរសជន ដៃគូអភិវឌ្ឍ ស្ថាប័នឯកជនជាតិ ឬអន្តរជាតិនានា
- កម្រៃសេវាផ្សេងៗពីវិស័យបរិស្ថាន
- ប្រភពផ្សេងៗទៀត។

**មាត្រា៩.-**

ម.ប.ស ត្រូវរក្សាទុកក្នុងគណនីមួយរបស់រតនាគារជាតិ ឬធនាគារពាណិជ្ជជាដៃគូណាមួយ តាមការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១០.-**

មូលនិធិបរិស្ថាននិងសង្គម ត្រូវប្រើប្រាស់ក្នុងសកម្មភាព ដូចខាងក្រោម៖

- ការគាំពារបរិស្ថាន ការអភិរក្សព្រៃឈើ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ប្រកបដោយនិរន្តរភាព និងការរស់នៅប្រកដោយចីរភាព
- ការស្តារបរិស្ថាននិងកែលម្អធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីឡើងវិញ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនដែលរស់ក្នុងនិងក្បែរតំបន់គម្រោងអភិវឌ្ឍន៍ ឬតំបន់ផ្សេងទៀត
- ការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី
- ការស្រាវជ្រាវបច្ចេកទេសនិងវិទ្យាសាស្ត្រលើវិស័យបរិស្ថាន
- ការផ្សព្វផ្សាយអំពីវិស័យបរិស្ថាន
- ទ្រទ្រង់កម្មវិធីបង្កើតសហគមន៍ការពារធម្មជាតិនិងសហគមន៍នានាបម្រើឱ្យវិស័យបរិស្ថាន
- ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យបរិស្ថាននិងធនធានធម្មជាតិ
- ការអប់រំផ្សព្វផ្សាយលើតំបន់ការពារធម្មជាតិ។

**មាត្រា១១.-**

នីតិវិធីនៃការគ្រប់គ្រងការប្រមូលចំណូល និងការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ២៣៩ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៩ មាត្រា១០ មាត្រា៤២ និងមាត្រា៤៥ នៃអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រាមួយ .-**

ត្រូវបានកែសម្រួលមាត្រា៩ មាត្រា១០ មាត្រា៤២ និងមាត្រា៤៥ នៃអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ៩ ថ្មី .-**

ខុទ្ទកាល័យរដ្ឋមន្ត្រី មានតួនាទីធ្វើជាសេនាធិការជូនរដ្ឋមន្ត្រីផ្ទាល់ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ទំនាក់ទំនងជាមួយខុទ្ទកាល័យរបស់ប្រមុខរាជរដ្ឋាភិបាល ខុទ្ទកាល័យរដ្ឋមន្ត្រីនានា អ្នកតំណាងរាស្ត្រ ស្ថាប័នពាក់ព័ន្ធ អគ្គនាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ និងប្រព័ន្ធផ្សព្វផ្សាយ
- លើកយោបល់ជូនរដ្ឋមន្ត្រី ចំពោះសំណុំរឿងទាំងឡាយដែលប្រធានស្ថាប័នបានប្រគល់ឱ្យ ។

- ត្រួតពិនិត្យ និងចាត់ឱ្យប្រថាប់ត្រាលើលិខិតបទដ្ឋានគតិយុត្ត លិខិតឯកត្តភូត និងលិខិតស្នាមផ្សេងៗ ដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រី

- តាមដាន និងសម្របសម្រួលសកម្មភាពទាំងឡាយរបស់ក្រសួងមហាផ្ទៃ ដើម្បីសម្រួលការងារ និងតាមដានការអនុវត្តបញ្ជារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- សហការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ អង្គភាពចំណុះក្រសួង រៀបចំកាលវិភាគបំពេញការងារជូនរដ្ឋមន្ត្រី និងតាមដានការអនុវត្តទាំងនេះឱ្យស្របតាមកាលវិភាគ ដែលបានកំណត់

- ជំនួយការផ្ទាល់រដ្ឋមន្ត្រី លើការងារព័ត៌មានទូទៅ ការងារភស្តុភារ គណនេយ្យ និងបុគ្គលិក

- អនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀត ដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**ខុទ្ទកាល័យរដ្ឋមន្ត្រី** ដឹកនាំដោយនាយកខុទ្ទកាល័យ **មួយរូប** និងមាននាយករងខុទ្ទកាល័យព្រមទាំងសមាជិកខុទ្ទកាល័យ **មួយចំនួន** ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១០ ថ្មី .-**

**អគ្គលេខាធិការដ្ឋាន** មានតួនាទីធ្វើជាសេនាធិការជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ទទួលពិនិត្យ និងចាត់ចែងនូវរាល់លិខិតចេញ-ចូល ដែលអង្គភាពចំណុះទីស្តីការក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាផ្សេងទៀត ផ្ញើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- ពិនិត្យរាល់ឯកសារ ដែលចុះហត្ថលេខាដោយរដ្ឋលេខាធិការ តាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រី

- បញ្ជូនបញ្ជារបស់រដ្ឋមន្ត្រីទៅបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ និងសាលារាជធានី ខេត្ត

- ទំនាក់ទំនងសាធារណៈ សហការពិនិត្យដោះស្រាយទទួល បញ្ជូនលិខិតស្នាមរដ្ឋបាល ឯកសារផ្សេងៗទៀត ពីក្រសួងមហាផ្ទៃទៅក្រសួង ស្ថាប័ននានាតាមការកំណត់របស់ក្រសួង

- ទំនាក់ទំនង សម្របសម្រួលជាមួយខុទ្ទកាល័យរបស់រដ្ឋមន្ត្រី ស្ថាប័នពាក់ព័ន្ធ និងប្រព័ន្ធផ្សព្វផ្សាយនានាក្នុងការអនុវត្តបទបញ្ជារបស់រដ្ឋមន្ត្រី

- សហការ សម្របសម្រួលជាមួយអង្គភាពចំណុះក្រសួង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កលក្ខណៈជូនទីប្រឹក្សា ជំនួយការរដ្ឋមន្ត្រី និងទីប្រឹក្សា ជំនួយការក្រសួង បំពេញការងារតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីស្របតាមជំនាញ និងបទពិសោធន៍

- ទំនាក់ទំនង សហការសម្របសម្រួលការងារអន្តរជាតិ ជាមួយស្ថានទូត ក្រសួងមហាផ្ទៃ ក្រសួងសន្តិសុខជាតិ នៃបណ្តាប្រទេសនានា ទាំងក្នុងតំបន់ និងសកលលោក ដែលពាក់ព័ន្ធការងាររដ្ឋបាលដែនដី និងនគរបាលជាតិ តាមការកំណត់របស់ក្រសួងមហាផ្ទៃ

- សិក្សាគោលការណ៍ និងរៀបចំផែនការសកម្មភាពព័ត៌មានវិទ្យារបស់ក្រសួង ដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខ អភិបាលកិច្ច និងការអភិវឌ្ឍ

- ប្រមូលព័ត៌មាន ទិន្នន័យ តាមដានសារព័ត៌មាន និងឯកសារផ្សេងៗ ដែលត្រូវផ្សព្វផ្សាយលើគេហទំព័រ ដើម្បីបកស្រាយបំភ្លឺ និងឆ្លើយតប

- តាមដានការប្រតិបត្តិនូវរាល់លិខិតបទដ្ឋានគតិយុត្ត បទបញ្ជា សេចក្តីជូនដំណឹង ផែនការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ ដែលត្រូវផ្សព្វផ្សាយទូលំទូលាយជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិ

- រៀបចំដំណើរបេសកកម្ម ទស្សនកិច្ចក្នុង និងក្រៅប្រទេសជូនថ្នាក់ដឹកនាំក្រសួង

- រៀបចំកិច្ចប្រជុំសន្និបាត សន្និសីទ សិក្ខាសាលា ពិធីបុណ្យផ្សេងៗ និងទទួលបដិសណ្ឋារកិច្ចភ្ញៀវជាតិ និងអន្តរជាតិ

- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋាននានា ដែលមានការពាក់ព័ន្ធដល់សមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ដាក់ជូនថ្នាក់ដឹកនាំក្រសួង ពិនិត្យនិងសម្រេច

- ការពារសន្តិសុខសណ្តាប់ធ្នាប់ រៀបចំតុបតែង ថែរក្សាអនាម័យបរិវេណទីស្តីការក្រសួងមហាផ្ទៃ

- គ្រប់គ្រងឯកសារ ការងារបុគ្គលិក ការងារភស្តុភារ និងគណនេយ្យរបស់ថ្នាក់ដឹកនាំក្រសួង មន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិ ស្ថិតក្នុងក្របខ័ណ្ឌអគ្គលេខាធិការដ្ឋានតាមការកំណត់របស់ក្រសួង

- គ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិ ក្រោមឱវាទ ធ្វើការវាយតម្លៃស្នើសុំតែងតាំងមុខតំណែង ផ្ទេរភារកិច្ច ដំឡើងឋានន្តរស័ក្តិ ថ្នាក់ លើកសរសើរ ឬដាក់វិន័យ តាមបែបបទ និងនីតិវិធី ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ពិនិត្យនិងសម្រេច

- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់ក្រសួងមហាផ្ទៃ និងអគ្គលេខាធិការដ្ឋានតាមការកំណត់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- ទទួលអនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**អគ្គលេខាធិការដ្ឋាន** ដឹកនាំដោយអគ្គលេខាធិការ **មួយរូប** និងមានអគ្គលេខាធិការរង មួយចំនួនជាជំនួយការតាមការកំណត់ ។

**អគ្គលេខាធិការដ្ឋាន មានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖**

១- នាយកដ្ឋានកិច្ចការរដ្ឋបាល

២- នាយកដ្ឋានសរុប និងស្ថិតិ

៣- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

៤- នាយកដ្ឋានព័ត៌មានវិទ្យា

៥- លេខាធិការដ្ឋានកិច្ចការទីប្រឹក្សា និងជំនួយការ ។

ការរៀបចំតួនាទី ភារកិច្ច រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ការិយាល័យ ចំណុះឱ្យនាយកដ្ឋាន និងលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤២ ថ្មី .-**

**នាយកដ្ឋានប្រតិបត្តិ** មានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានពន្ធនាគារ លើការងាររៀបចំ លិខិតបទដ្ឋាន អនុវត្តច្បាប់ នីតិវិធី និងបទបញ្ញានានាទាក់ទងនឹងការងារធ្វើចំណាត់ថ្នាក់សន្តិសុខ ការងារឃុំឃាំង ការអនុវត្តសាលក្រម សាលដីកា ប័ណ្ណសារ និងគ្រប់គ្រងទិន្នន័យជនជាប់ឃុំ ដែលមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំសេចក្តីណែនាំ លិខិតបទដ្ឋាន បទបញ្ញានានា ស្តីពីការអនុវត្តសាលក្រម សាលដីការបស់សាលាជម្រះក្តី និងការងារគ្រប់គ្រងសំណុំឯកសារជនជាប់ឃុំ តាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត

- គ្រប់គ្រង ណែនាំរាល់សកម្មភាពអនុវត្តច្បាប់ នីតិវិធី និងបទបញ្ញា ក្នុងការងារឃុំឃាំងជនជាប់ឃុំ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់

- គ្រប់គ្រងការធ្វើចំណាត់ថ្នាក់សន្តិសុខជនជាប់ឃុំតាមនីតិវិធី

- ចាត់វិធានការឃុំឃាំងជនជាប់ឃុំឱ្យបានត្រឹមត្រូវតាមបទដ្ឋានកំណត់ និងដើម្បីសម្រួលដល់ការស៊ើបអង្កេតរបស់អាជ្ញាធរមានសមត្ថកិច្ច

- ណែនាំអំពីជំនាញឆែកឆេរសម្ភារ និងវត្ថុហាមឃាត់នៅក្នុងអាគារឃុំឃាំង

- ដឹកនាំ ណែនាំផ្នែកជំនាញដល់មន្ត្រីនៅមណ្ឌលអប់រំកែប្រែ និងនៅតាមពន្ធនាគាររាជធានី ខេត្ត ក្នុងការអនុវត្តដីកា សាលក្រម សាលដីការបស់តុលាការគ្រប់ថ្នាក់

- ចាត់តាំងកម្មវិធីបណ្តុះបណ្តាល ហ្វឹកហាត់ បំប៉នជំនាញឯកទេស ធ្វើប័ណ្ណសារ និងគ្រប់គ្រងទិន្នន័យច្បាប់ ដល់មន្ត្រីជំនាញតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត

- ចាត់តាំងផ្សព្វផ្សាយ ការអនុវត្តសាលក្រម សាលដីកា ការព្យួរទោស និងការបណ្តេញចេញទៅក្រៅ ប្រទេស

- ពិនិត្យ វាយតម្លៃជនជាប់ឃុំដែលទទួលបានសាលក្រម សាលដីកាស្ថាពរ ដើម្បីបំពេញកាតព្វកិច្ចការអនុវត្តសាលក្រម តាមរយៈចាត់តាំងធ្វើពលកម្មបម្រើសំណូមពរការបណ្តុះបណ្តាលវិជ្ជាជីវៈ រៀនសូត្រ ចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម និងកសិកម្មពន្ធនាគារនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត

- ធ្វើអធិការកិច្ចតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ វាយតម្លៃរាល់ការអនុវត្តច្បាប់ នីតិវិធី លិខិតបទដ្ឋាន បទបញ្ជា និងសេចក្តីណែនាំស្តីពីការគ្រប់គ្រងសំណុំឯកសារជនជាប់ឃុំ

- បង្កើត និងគ្រប់គ្រងប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យាស្តីពីការគ្រប់គ្រងជនជាប់ឃុំ

- គ្រប់គ្រងសំណុំឯកសារ និងធ្វើប័ណ្ណសារជនជាប់ឃុំ តាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត

- គ្រប់គ្រងទិន្នន័យស្ថិតិជនជាប់ឃុំតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត

- គ្រប់គ្រង ស្រាវជ្រាវ ពិនិត្យតាមដាន ជនជាប់ឃុំពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ បណ្តឹងសារទុក្ខ និងការប្តឹងទាស់នានា

- សហការជាមួយនាយកដ្ឋានរដ្ឋបាលសរុប និងនាយកដ្ឋានពាក់ព័ន្ធនានា រៀបចំបង្កើតបទដ្ឋានគំរូពាក់ព័ន្ធសំណុំឯកសារនានារបស់ជនជាប់ឃុំ ដើម្បីស្នើសុំបោះពុម្ពផ្តល់ជូនមណ្ឌលអប់រំកែប្រែ និងពន្ធនា-គាររាជធានី ខេត្ត

- ពិនិត្យទម្រង់បែបបទ ការធ្វើបត្យាប័ន និងការផ្ទេរជនជាប់ឃុំពីពន្ធនាគារមួយទៅពន្ធនាគារមួយ

- ពិនិត្យសំណើផ្ទេរជនជាប់ឃុំពីពន្ធនាគារ ដែលចង្អៀតណែនលើសបទដ្ឋានកំណត់ ដើម្បីបញ្ជូនទៅពន្ធនាគារផ្សេងទៀត

- សហការរួមមតិយោបល់ វាយតម្លៃ អំពីកម្រិតកែប្រែរបស់ជនជាប់ឃុំម្នាក់ៗ ដើម្បីមានមូលដ្ឋានលើកសំណើបន្ធូរបន្ថយទោស និងលើកលែងទោស

- បូកសរុប វាយតម្លៃ សភាពការណ៍ប្រែប្រួលជនជាប់ឃុំ អំពីកំណើន និងការថយចុះប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ផ្តល់យោបល់ពីការកំណត់តួលេខស្នើសុំផ្តល់របបជីវភាពជនជាប់ឃុំតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត

- ធ្វើការងារបុគ្គលិក ភស្តុភារ គណនេយ្យរបស់នាយកដ្ឋាន

- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានប្រតិបត្តិតាមការកំណត់ជូនអគ្គនាយកដ្ឋានពន្ធនាគារ

- ទទួលអនុវត្តការងារផ្សេងៗទៀត ដែលអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារប្រគល់ឱ្យ

នាយកដ្ឋានប្រតិបត្តិ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន តាមការកំណត់

**មាត្រា ៤៥ ថ្មី .-**

**នាយកដ្ឋានសន្តិសុខពន្ធនាគារ** មានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានពន្ធនាគារ លើការងាររក្សាសន្តិសុខ សុវត្ថិភាព និងបង្ការទប់ស្កាត់រាល់ឧបាយកលនានា ដែលមានភារកិច្ចដូចខាងក្រោម ៖

- សហការជាមួយអង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច បង្ការទប់ស្កាត់ និងប្រឆាំងរាល់ឧបាយកល បង្កចលាចល វិទ្ធង្សនា បំផ្លិចបំផ្លាញ ឃាតកម្ម អត្តឃាត លួចរត់ និងសកម្មភាពរំដោះជនជាប់ឃុំ
- សិក្សាស្រាវជ្រាវអំពីយុទ្ធសាស្ត្រ យុទ្ធវិធីក្នុងការការពារគោលដៅប៉ុស្តិ៍ប៉មពន្ធនាគារ គោលដៅសិប្បកម្ម កសិដ្ឋាន ទីលានហាត់ប្រាណ ទីលានសិល្បៈ កីឡារបស់ជនជាប់ឃុំ ដើម្បីចាត់វិធានការធានាសន្តិសុខ សុវត្ថិភាព ជាក់ស្តែង
- ស្រាវជ្រាវ ប្រមូលព័ត៌មានទាក់ទងដល់សកម្មភាពរបស់ជនជាប់ឃុំ ដែលអាចឈានទៅបង្កផលប៉ះពាល់ដល់ សន្តិសុខ សុវត្ថិភាពក្នុងពន្ធនាគារ និងទំនាក់ទំនងឧក្រិដ្ឋកម្មផ្សេងៗទៀតក្រៅពន្ធនាគារ
- ក្តាប់ព័ត៌មានផ្ទៃក្នុង និងសភាពការណ៍ ទាក់ទងដល់សន្តិសុខ សុវត្ថិភាពពន្ធនាគារ និងបណ្តាគោលដៅទាំងឡាយ ដែលជនជាប់ឃុំទៅធ្វើសកម្មភាព
- ត្រៀមកម្លាំងសហការជាមួយអង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីជួយអន្តរាគមន៍ដោះស្រាយរាល់ឧប្បត្តិហេតុដែលប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ពន្ធនាគារ និងគ្រោះធម្មជាតិ គ្រោះមហន្តរាយ ផ្សេងៗដែលអាចកើតមាននៅតាមពន្ធនាគារដោយថាហេតុ
- សហការ និងចាត់ចែងកម្លាំងដឹកជញ្ជូនជនជាប់ឃុំដែលត្រូវចល័តពីពន្ធនាគារមួយទៅពន្ធនាគារមួយ និងដឹកជញ្ជូនជនជាប់ឃុំឡើងសវនាការសាលាឧទ្ធរណ៍ និងតុលាការកំពូល
- សហការដឹកជញ្ជូនជនជាប់ឃុំពីក្នុងទៅក្រៅប្រទេស និងពីក្រៅចូលក្នុងប្រទេសវិញ
- អន្តរាគមន៍ការពារជនជាប់ឃុំក្នុងករណីចាំបាច់ ដូចជា សវនាការមុខសញ្ញាសំខាន់ៗ ឬការពារជនជាប់ឃុំពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ (រាជធានីភ្នំពេញ)
- កសាងផែនការបណ្តុះបណ្តាលមន្ត្រីពន្ធនាគារ ស្តីពីការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព ការដោះស្រាយ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ
- ចាត់តាំងហ្វឹកហ្វឺន លំហាត់របៀប លំហាត់ក្បាច់គុណ ការប្រើប្រាស់អាវុធ និងឧបករណ៍បច្ចេកទេសឱ្យបានស្ទាត់ជំនាញ
- ណែនាំអំពីជំនាញផែកឆេះ សម្ភារ ខ្លួនប្រាណ ក្នុងបរិវេណពលកម្ម ព្រមទាំងការប្រើប្រាស់ឧបករណ៍ ស្កេនដោយដៃ និងស្វ័យប្រវត្តិ
- សហការជាមួយអង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្វែងរកចាប់ខ្លួនជនជាប់ឃុំដែលរត់គេចខ្លួន
- សហការរួមមតិយោបល់ វាយតម្លៃ អំពីកម្រិតកែប្រែរបស់ជនជាប់ឃុំម្នាក់ៗ ដើម្បីមានមូលដ្ឋានលើកសំណើបន្ធូរបន្ថយទោស និងលើកលែងទោស
- សហការរួមមតិយោបល់ លើការងារថែទាំ ជួសជុល សាងសង់ហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារពាក់ព័ន្ធនឹងការងារថែរក្សាសន្តិសុខ សុវត្ថិភាពពន្ធនាគារ
- ធ្វើការងារបុគ្គលិក ភស្តុភារ គណនេយ្យរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានសន្តិសុខតាមការកំណត់ជូនអគ្គនាយកដ្ឋានពន្ធនាគារ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារប្រគល់ឱ្យ

នាយកដ្ឋានសន្តិសុខពន្ធនាគារ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការកំណត់ ។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យស្តីពីកែសម្រួលនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
**សូមហត្ថលេខា**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន និង នាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន និងនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម ចំណុះនាយកដ្ឋានកណ្ដាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

**មាត្រា២ .-**

**នាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន** មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើជាសេនាធិការជូននាយកដ្ឋានកណ្ដាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ លើការងារត្រួតពិនិត្យបែបបទសំណុំឯកសារពាក់ព័ន្ធការស្នើសុំច្បាប់អនុញ្ញាតធ្វើអាជីវកម្មផ្នែកសន្តិសុខឯកជន និងជ្រើសរើសកម្លាំងភ្នាក់ងារសន្តិសុខឯកជន ។/.

- ផ្តល់ការហ្វឹកហ្វឺន បណ្តុះបណ្តាលជំនាញឯកទេស និងច្បាប់ដល់កងកម្លាំងភ្នាក់ងារសន្តិសុខឯកជន និងចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សា ។
- គ្រប់គ្រងសកម្មភាពរបស់បណ្តាក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន សហគ្រាស គ្រឹះស្ថានសន្តិសុខឯកជន អនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍កំណត់ ។
- ត្រួតពិនិត្យការប្រើប្រាស់ឧបករណ៍ សម្ភារបច្ចេកទេស មធ្យោបាយ ឬសត្វ សម្រាប់បម្រើសកម្មភាពការពារសន្តិសុខ ។
- ផ្តល់កិច្ចសហការជាមួយក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន ការពារទីតាំងសំខាន់ៗ និងការដឹកជញ្ជូនប្រាក់ ទ្រព្យសម្បត្តិ វត្ថុមានតម្លៃស្របច្បាប់ ។
- លើកយោបល់ជូនអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ដើម្បីសុំគោលការណ៍លុបចោល ឬផ្អាកសកម្មភាពជាបណ្តោះអាសន្ន ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្ម ឬផ្តល់ឡើងវិញចំពោះក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន ដែលធ្វើសកម្មភាពផ្ទុយពីគោលការណ៍កំណត់ ។
- ជំរុញ ការលើកកម្ពស់វិស័យសន្តិសុខឯកជន ចូលរួមចំណែកការពារសន្តិសុខ និងថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ។
- ប្រមែប្រមូលព័ត៌មាន ធ្វើរបាយការណ៍អំពីសភាពការណ៍ និងហេតុការណ៍ផ្សេងៗតាមឋានានុក្រមជូនអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ តាមការកំណត់ ។
- ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ភស្តុភារ គណនេយ្យរបស់នាយកដ្ឋានតាមការកំណត់ ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**មាត្រា៣ .-**

**នាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម** មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើជាសេនាធិការជូននាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ លើការងារប្រយុទ្ធប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ ។
- សហការជាមួយម្ចាស់កាស៊ីណូ ក្លឹបកម្សាន្ត ដើម្បីត្រួតពិនិត្យបច្ចេកទេសល្បែង និងមុខសញ្ញាហាមឃាត់ចូលលេងល្បែង ។
- ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបការលេងល្បែងស៊ីសងគ្រប់ប្រភេទ ។
- ស្រាវជ្រាវ ស៊ើបអង្កេត បង្ក្រាបការសម្អាតប្រាក់ បទល្មើសពាក់ព័ន្ធនិងបច្ចេកទេសល្បែងក្នុងកាស៊ីណូ ក្លឹបកម្សាន្ត ។
- ត្រួតពិនិត្យការប្រើប្រាស់ឧបករណ៍ សម្ភារបច្ចេកទេសល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ ដើម្បីបម្រើឱ្យការងារជំនាញ ។
- ជំរុញ ការធ្វើអាជីវកម្មល្បែងពាណិជ្ជកម្មឱ្យអនុវត្តតាមគោលការណ៍ច្បាប់ ។
- គ្រប់គ្រងរមណីយដ្ឋាន ក្លឹមកម្សាន្ត និងល្បែងភ្នាល់គ្រប់ប្រភេទ តាមគោលការណ៍កំណត់ ។
- សិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលជំនាញបច្ចេកទេសល្បែងពាណិជ្ជកម្ម ។
- ធ្វើរបាយការណ៍ជូននាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ តាមការកំណត់។

- ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ភស្តុភារ គណនេយ្យរបស់នាយកដ្ឋាន តាមការកំណត់ ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**មាត្រា៤ .-**

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

**មាត្រា៥ .-**

នាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន មានការិយាល័យចំណុះមួយចំនួន និងនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម មានការិយាល័យចំណុះមួយចំនួន ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
**សូមហត្ថលេខា**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល</u> :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៤១ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

<u>**សម្រេច**</u>

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៤ ៨៤០ ០០០ ០០០ រៀល (បួនបីលានប្រាំបីរយសែសិបលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦០ (ការទិញ) ជូនក្រសួងមហាផ្ទៃ (រដ្ឋបាលទូទៅ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយលើស្បៀងអាហាររបស់ពិរុទ្ធជន និងទណ្ឌិតក្នុងរយៈពេល ០៣ខែ ចុងឆ្នាំ ២០១៦។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៨៧ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការបង្កើតស្ថានតំណាងអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា អមលេខាធិការដ្ឋានអាស៊ាន នៅទីក្រុងហ្សាការតា (ប្រទេសឥណ្ឌូនេស៊ី)

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

### សម្រេច

**មាត្រា ១** : ត្រូវបានបង្កើត **ស្ថានតំណាងអចិន្ត្រៃយ៍** នៃព្រះរាជាណាចក្រកម្ពុជា**អមលេខាធិការដ្ឋានអាស៊ាន** ដោយមាននិវេសនដ្ឋាននៅទីក្រុងហ្សាការតា (ប្រទេសឥណ្ឌូនេស៊ី)។

**មាត្រា ២** : ស្ថានតំណាងអចិន្ត្រៃយ៍នេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មម្នាក់ដែលមានឋានៈស្មើឯកអគ្គរាជទូត។

**មាត្រា ៣** : សមាសភាពមន្ត្រីការទូតផ្សេងទៀត មន្ត្រីបច្ចេកទេស និងបុគ្គលិកសេវា នឹងត្រូវកំណត់តាមតម្រូវការនៃការងារជាក់ស្ដែង។

**មាត្រា ៤** : ប្រព័ន្ធហិរញ្ញកិច្ចសម្រាប់មន្ត្រីការទូត មន្ត្រីបច្ចេកទេស និងបុគ្គលិកសេវានៃស្ថានតំណាងអចិន្ត្រៃយ៍នេះ ត្រូវស្ថិតក្នុងប្រភេទ "ខ"។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ [illegible] ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល ៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :...២៤៣...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១ ៥៨៤ ០០០ ០០០ រៀល (មួយពាន់ប្រាំរយប៉ែតសិបបួនលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦០ (ការទិញ) ចំនួន ២២២ ៣០០ ០០០ រៀល និងជំពូក ៦១ (សេវាកម្ម) ចំនួន ១ ៣៦១ ៧០០ ០០០ រៀល ជូនក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ជួសជុលកែលម្អអគារ ហេដ្ឋារចនាសម្ព័ន្ធ បំពាក់ឧបករណ៍ សម្ភារ និងតបណ្តាញទឹកស្អាតពីស្ថានីយ៍ចម្រោះទឹកស្អាតមកទីស្នាក់ការប៉ុស្តិ៍ត្រួតពិនិត្យច្រកទ្វារអន្តរជាតិត្រពាំងក្រៀល ដើម្បីត្រៀមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួមជាមួយភាគីឡាវ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៤៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ២៨៤ ៣០០ ០០០ រៀល (ពីររយប៉ែតសិបបួនលានបីរយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦០ (ការទិញ) ជូនក្រសួងបរិស្ថាន សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ចំណាយលើថ្លៃអគ្គិសនីក្នុងឆ្នាំ ២០១៦។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១១៣១ .អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបញ្ចប់មុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ ៖** បញ្ចប់មុខតំណែងលោកឧត្តមសេនីយ៍ទោ **រស់ ឧស្សាហ៍** អត្តលេខ ៦៥៨៨៨ ពីអគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ក្រសួងមហាផ្ទៃ។

**មាត្រា ២ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៣៧ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពី គោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** ដាក់មន្ត្រីរាជការ ចំនួន ០៦ នាក់ របស់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យចូលនិវត្តន៍មុនកាលកំណត់តាមការស្នើសុំ ក្នុងឋានន្តរស័ក្តិវរមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១- លោក **កែវ ភក្តី** | វរមន្ត្រី ថ្នាក់លេខ ២ ឱ្យចូលនិវត្តន៍ ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៦ |
| ២- លោក **មៀន គុងហ៊ី** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ ឱ្យចូលនិវត្តន៍ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ |
| ៣- លោក **ឡុង មុត** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ ឱ្យចូលនិវត្តន៍ ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ |
| ៤- លោកស្រី **ជា ច័ន្ទដានី** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ ឱ្យចូលនិវត្តន៍ ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៦ |
| ៥- លោក **ហេង តិចហុង** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ ឱ្យចូលនិវត្តន៍ ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ |
| ៦- លោក **ថៃ ជា** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ ឱ្យចូលនិវត្តន៍ ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៦ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូច មានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១១៣៣ អនុក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងថ្នាក់តាមវេនប្រចាំឆ្នាំ ដល់មន្ត្រីរាជការចំនួន ៦៧ រូប ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចាប់ពីថ្ងៃទី ១៣ ខែ **មេសា** ឆ្នាំ **២០១៦** ដូចមាននាមខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក **អ៊ុំ សុផាន់ណារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ២- លោកស្រី **អ៊ុង វណ្ណឫទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ៣- លោកស្រី **វង្ស វិសេដ្ឋា** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ៤- លោក **សោម សំអឿន** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ៥- លោក **ទិត វ៉ាល់ដា** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ៦- លោកស្រី **ទេព សុជាតា** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ៧- លោក **កែត ធឿន** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ៨- លោក **រស់ ទី** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ៩- លោក **អ៊ុង គៀនហេង** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ១០- លោក **ឃុន វុទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ១១- លោក **គង់ រឿង** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ១២- លោក **សេង គឹមសាន** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ១៣- លោក **ចូវ សង្វៀប** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ១៤- លោក **កែវ ភាន** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ១៥- លោក **ប៊ី ជា** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ១៦- លោក **ចាន់ សុខុម** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ **១** |
| ១៧- លោកស្រី **ម៉ូ ស៊ីថា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ **២** |
| ១៨- លោក **ប៉ែ សំបូរ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ **២** |
| ១៩- លោក **សូលី វណ្ណប៉ុក** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ **២** |
| ២០- លោក **ឡៅ ម៉េង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ **២** |
| ២១- លោកស្រី **ចាន់ តារិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ **២** |
| ២២- លោក **ទូច រចនា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ **២** |

| | | |
|---|---|---|
| ២៣- លោក **យស់ សំអុល** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៤- លោក **អំ សុខហេង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៥- លោក **លី មៃ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៦- លោកស្រី **ម៉ៅ សួស្តី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៧- លោក **មុំ ធីរៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៨- លោកស្រី **ជា សីដាលី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៩- លោក **សុត ចាន់វណ្ណាៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣០- លោក **ខ្លូង ពិចិត្រ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣១- លោក **ចាន វ៉ាឌុធ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣២- លោក **មាស វ៉ាមី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៣- លោកស្រី **សម សោភា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៤- លោក **ប៉ែន ជីវ័ន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៥- លោក **ហេង វឌ្ឍីរិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៦- លោក **លុយ ច័ន្ទឫទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៧- លោក **សុខ ចាន់ថុល** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៨- លោកស្រី **ស៊ាន ប៉ូលីន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៩- លោកស្រី **គង់ គីណា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤០- លោក **គឹម គេង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤១- លោក **អ៊ុន លំអេង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤២- លោក **គី ចាន់ថា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៣- លោក **គង់ សុខលី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៤- លោក **តែ គង់** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៥- លោក **ត្បូង សិទ្ធិ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៦- លោក **សំ សាវ៉ាក់** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៧- លោកស្រី **សេក ទេវី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៨- លោក **លី ឡេងមន្លីកែវ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៩- លោកស្រី **ថេម សិខាមណី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |

| | | |
|---|---|---|
| ៥០- លោកស្រី **ប្រុក ម៉ៃកនិដ្ឋា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥១- លោក **ជួរ រតនៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥២- លោក **អួច គន្ធាច័រ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥៣- លោក **ទៀន រិទ្ធីរត្ន័** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥៤- លោក **ញ៉ៀប ចាន់ណោ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥៥- លោក **អៀម សារ៉ាត** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**

លេខ..០៧..គសសអ

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១៦

# សេចក្តីណែនាំ

**យោង** :
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ផែនការអន្តរស្ថាប័នលេខ ០០៩ ផ.ក /១៦ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោតរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប
- សេចក្តីណែនាំរួមលេខ ០១៨ សណន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត
- ប្រកាសលេខ ១០២៤៥ ប្រក ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ដោយអាជ្ញាធរឃុំ សង្កាត់ជូនប្រជាពលរដ្ឋសម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត
- បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦
- លិខិតលេខ ១០៣១ /១៦ គ.ជ.ប ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៦ ស្តីពីសំណើមានវិធានការ និងអន្តរាគមន៍ដល់អង្គភាពនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទដែលមានមូលដ្ឋានឈរជើង ឬបំពេញបេសកកម្មនៅក្នុងរាជធានី ខេត្ត ។

កន្លងមកមានមជ្ឈដ្ឋានមួយចំនួនបានលើកឡើងថា មានកងកម្លាំងនគរបាលជាតិ កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទមួយចំនួន ត្រូវបានចាត់ឲ្យទៅចុះឈ្មោះបោះឆ្នោតនៅតាមមូលដ្ឋាននានាដែលមិនមែនជាទីលំនៅ ឬទីសំណាក់របស់ខ្លួន ដែលជាទង្វើរំលោភច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត និងផ្ទុយពីឆន្ទៈសាមីខ្លួន ។ ជាទូទៅ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទតែងតែឈរជើង និងស្នាក់នៅក្នុងមូលដ្ឋានប្រមូលផ្តុំនានាដែលជាទីតាំងជាក់លាក់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។ ក្រៅពីនេះកងកម្លាំងមួយចំនួនក៏ត្រូវបានចាត់តាំងឲ្យទៅបំពេញបេសកកម្មជាកម្លាំងរក្សាសន្តិសុខក្នុងដំណើរការបោះឆ្នោត នៅតាមមូលដ្ឋានមួយចំនួនដែលមិនមែនជាទីតាំងឈរជើង ឬទីសំណាក់របស់ខ្លួន ។

ផ្អែកតាមច្បាប់ស្តីពីការបោះឆ្នោត កងកម្លាំងនគរបាលជាតិ កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទគ្រប់រូប គឺមានសិទ្ធិចុះឈ្មោះបោះឆ្នោត និងបោះឆ្នោតនៅឃុំ សង្កាត់ដែលខ្លួនស្នាក់នៅ ដូចប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតដទៃទៀតដែរ និងត្រូវបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ និងបោះឆ្នោតដែលបានកំណត់ដោយ គ.ជ.ប ។

ក្នុងគោលដៅធានាសិទ្ធិ និងបង្កលក្ខណៈងាយស្រួយដល់កងកម្លាំងនគរបាលជាតិ កងរាជអាវុធហត្ថ និងកងយុទ្ធពលខេមភូមិន្ទដែលមានមូលដ្ឋានឈរជើង ឬបំពេញបេសកកម្ម ឬត្រូវបានចាត់តាំងឲ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោតនៅតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្តទូទាំងប្រទេសបានចុះឈ្មោះបោះឆ្នោត និងបោះឆ្នោតស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សូមធ្វើការណែនាំដូចតទៅ ៖

<u>ក. នគរបាលជាតិ ឬយោធិនក្នុងមូលដ្ឋានឈរជើងដែលស្ថិតក្នុងភូមិសាស្ត្រឃុំ សង្កាត់ ហើយដែលត្រូវសុំចុះឈ្មោះបោះឆ្នោត</u> ៖

- មេបញ្ជាការ ឬថ្នាក់ដឹកនាំនៃអង្គភាពត្រូវធ្វើទំនាក់ទំនង និងសម្របសម្រួលស្នើសុំអាជ្ញាធរឃុំ សង្កាត់នៃមូលដ្ឋានឈរជើងរបស់ខ្លួន ដើម្បីចេញលិខិតបញ្ជាក់ទីលំនៅសំរាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមប្រកាសលេខ ១០២៤៥ ប្រក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋសម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត ដោយយកទីតាំងដែលខ្លួនឈរជើងជាទីសំណាក់ ។
- មេបញ្ជាការ ឬថ្នាក់ដឹកនាំនៃអង្គភាពត្រូវណែនាំដល់សមាជិកកងនគរបាលជាតិ ឬយោធិនណាដែលមានទីលំនៅ ឬទីសំណាក់ខាងក្រៅមូលដ្ឋានឈរជើង ដើម្បីទៅចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់នៃទីលំនៅ ឬទីសំណាក់របស់ខ្លួន ស្របតាមបែបបទ នីតិវិធីកំណត់ដូចប្រជាពលរដ្ឋទូទៅ ។
- មេបញ្ជាការ ឬប្រធានអង្គភាពត្រូវធ្វើទំនាក់ទំនង និងសម្របសម្រួលស្នើសុំអាជ្ញាធរឃុំ សង្កាត់នៃមូលដ្ឋានឈរជើង ដើម្បីចេញលិខិតបញ្ជាក់អត្តសញ្ញាណជូន ស្របតាមសេចក្តីណែនាំរួមលេខ ០១៨ សណន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០១៦ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតចំពោះសមាជិកកងនគរបាលជាតិ ឬយោធិនណាដែលគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

<u>ខ- នគរបាលជាតិ ឬយោធិន ឬសន្តិសុខបោះឆ្នោតបំពេញបេសកកម្មរយៈពេលយូរហូតដល់ថ្ងៃបោះឆ្នោតឃុំ សង្កាត់ និងកងកម្លាំងសន្តិសុខបោះឆ្នោតដែលត្រូវមានបេសកកម្មការពារសន្តិសុខនៅថ្ងៃបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ</u> ៖

- មេបញ្ជាការ ឬថ្នាក់ដឹកនាំនៃអង្គភាព ដែលបានចាត់តាំងមន្ត្រីរបស់ខ្លួនឲ្យទៅឈរជើង និងបំពេញបេសកកម្មរហូតដល់ថ្ងៃបោះឆ្នោត ឬបានចាត់តាំងឲ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោតនៅតាមឃុំ សង្កាត់នៃរាជធានី ខេត្តនីមួយៗ ត្រូវរៀបចំលិខិតបញ្ជាបេសកកម្ម លិខិតឧទ្ទេសនាម ឬក៏លិខិតបង្គាប់ការជូនមន្ត្រីទាំងនោះឲ្យបានត្រឹមត្រូវតាមការកំណត់ ។

- មេបញ្ជាការ ឬ ថ្នាក់ដឹកនាំអង្គភាពនីមួយៗត្រូវធ្វើទំនាក់ទំនង និងសម្របសម្រួលស្នើសុំទៅអាជ្ញាធរឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវលិខិតបញ្ជាបេសកកម្ម លិខិតឧទ្ទេសនាម ឬក៏លិខិតបង្គាប់ការនោះ ដើម្បីឲ្យអាជ្ញាធរឃុំ សង្កាត់នៃទីកន្លែងដែលសមាជិកនគរបាលជាតិ ឬយោធិននោះឈរជើងបំពេញភារកិច្ចការពារសន្តិសុខសម្រាប់ដំណើរការបោះឆ្នោត បំពេញនីតិវិធីបែបបទក្នុងការចេញលិខិតបញ្ជាក់ទីលំនៅ សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត ។

- មេបញ្ជាការ ឬថ្នាក់ដឹកនាំអង្គភាពនីមួយៗត្រូវធ្វើទំនាក់ទំនង និងសម្របសម្រួលស្នើសុំអាជ្ញាធរឃុំ សង្កាត់នៃមូលដ្ឋានឈរជើង ដើម្បីចេញលិខិតបញ្ជាក់អត្តសញ្ញាណជូន ស្របតាមសេចក្តីណែនាំរួមលេខ ០១៨ សណន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ជូនចំពោះសមាជិកកងនគរបាលជាតិ ឬយោធិនណាដែលគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

គ. មេបញ្ជាការ ឬថ្នាក់ដឹកនាំអង្គភាពសាមីត្រូវពិនិត្យត្រៀមលក្ខណៈនិងរៀបចំជាមុននូវបញ្ជីឈ្មោះកងកម្លាំងដែលត្រូវបានចាត់តាំងជាភ្នាក់ងារសន្តិសុខបោះឆ្នោតសម្រាប់ការពារ តាមផែនការអន្តរស្ថាប័ន ដើម្បីឲ្យមន្ត្រីទាំងនោះងាយស្រួលក្នុងការចុះឈ្មោះបោះឆ្នោតឲ្យបានមុនថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាកំណត់ និងបានបោះឆ្នោតនៅជិតទីតាំងដែលសាមីខ្លួនត្រូវនៅបំពេញបេសកកម្ម ឬការពារគោលដៅការិយាល័យរបស់ខ្លួន ។

ទទួលបានសេចក្តីណែនាំនេះ សូមឯកឧត្តម អស់លោកជាមេបញ្ជាការ ឬថ្នាក់ដឹកនាំអង្គភាព និងកងកម្លាំងនគរបាលជាតិ កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទទាំងអស់ ត្រូវយកចិត្តទុកដាក់សហការសម្របសម្រួល និងអនុវត្តតាមគោលការណ៍ណែនាំនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាទៅ ។

ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

សម្តេចក្រឡាហោម ស ខេង

**<u>ចម្លងជូន</u>** ៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រឡាហោម ស ខេង
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ទៀ បាញ់

« ដើម្បីជូនជ្រាប »

- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
- បញ្ជាការដ្ឋានយោធភូមិភាគទាំង ៦
- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត
- បញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្ត
- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- សាលារាជធានី ខេត្ត

« ដើម្បីសហការអនុវត្ត »

- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១.៣.៥.៧ សហវ.ប្រក

## ប្រកាសរួម

## ស្តីពី

## ការផ្តល់ទឹកប្រាក់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រី ក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០០៤៤ អនក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ស្តីពីទិដ្ឋាការ - បញ្ជិកាឱសថ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទនិងល័ក្ខខ័ណ្ឌ នៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១២២ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងគ្រឿងសម្អាង
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា៦ នៃអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

- បានឃើញប្រកាសអន្តរក្រសួងលេខ ៨៦៨ ឧរថ.ប្រក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១០ ស្តីពីការអនុវត្តន៍ និងការរៀបចំសម្របសម្រួលស្ថាប័នកិច្ចនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារចាប់ពីកសិដ្ឋានផលិត ដល់តុបរិភោគ
- បានឃើញប្រកាសរួមលេខ ១០០២ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសរួមលេខ១៣៥៦ សហវ.ប្រក ចុះថ្ងៃទី១៨... ខែវិច្ឆិកា.. ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនក្រសួងសុខាភិបាល, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាលាជម្រះក្តីពាក់ព័ន្ធ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ និងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើស ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ២ .–**

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នារវាងរដ្ឋបាលកណ្តាល និង មន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងសុខាភិបាល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ៣ .–**

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលរាជធានី ខេត្ត បុរេប្រទានថវិការង្វាន់ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួន ពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ ដែលអនុវត្តតាមប្រកាសរួមលេខ១៣៥៦សហវ.ប្រក ចុះថ្ងៃទី១៨. ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងសុខាភិបាល។ ថវិការង្វាន់ដែលអនុញ្ញាតឱ្យបុរេប្រទាននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងសុខាភិបាល និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងចំណែកប្រាក់រង្វាន់របស់សាលាជម្រះក្តីពាក់ព័ន្ធ ក្នុងករណីមានការផ្តន្ទាទោសពិន័យជាប្រាក់ដែលអនុលោមតាមការសម្រេចរបស់សាលាជម្រះក្តី។

ប្រការ៤ .-

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ ដែលមានចែងក្នុងឧបសម្ព័ន្ធ១, ឧបសម្ព័ន្ធ២ និងឧបសម្ព័ន្ធ៣ នៃប្រកាសរួមលេខ១៣៥៤.៦សហវ.ប្រក ចុះថ្ងៃទី១៨..... ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល និងត្រូវបានបែងចែកដូចខាងក្រោម ÷

១- ចំពោះចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

ក១. ប្រាក់ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ លើប្រភេទសេវាមួយចំនួនដែលមានចែងក្នុងឧបសម្ព័ន្ធ១ ត្រូវបានបែងចែកតាមតារាងខាងក្រោម :

| ល.រ | បរិយាយប្រភេទសេវា | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. សុខាភិបាល | ក. សហវ |
| ១ | ការបណ្តុះបណ្តាលអនាម័យ និងសុវត្ថិភាពចំណីអាហារ ÷ | | | |
| | -បណ្តុះបណ្តាលអនាម័យនិងសុវត្ថិភាពចំណីអាហារដល់ចុងភៅ អ្នកគ្រប់គ្រង អ្នកបំរើសេវាកម្មម្ហូបអាហារ ក្នុងភោជនីយដ្ឋាន អាហារដ្ឋាន និងក្នុងសេវាធ្វើម្ហូបការ ម្ហូបបុណ្យ និងពិធីផ្សេងៗ | ១០% | ៨៩% | ១% |
| | -បណ្តុះបណ្តាលអនាម័យ និងសុវត្ថិភាពចំណីអាហារដល់បុគ្គលិកសិប្បកម្ម រោងចក្រផលិតចំណីអាហារ | ១០% | ៨៩% | ១% |
| ២ | ការផ្តល់លិខិតអនុញ្ញាតជូនគម្រោងសិក្សាស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស | ៣៥% | ៦៤% | ១% |
| ៣ | ការបង់ថ្លៃរបស់និស្សិតសម្រាប់រៀបចំការប្រឡងថ្នាក់ជាតិជ្រើសរើសនិស្សិតចូលរៀនកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររងក្នុងវិស័យសុខាភិបាល (និស្សិត ១នាក់) | ៤% | ៩៥% | ១% |
| ៤ | ការបង់ថ្លៃរបស់និស្សិតសម្រាប់រៀបចំការប្រឡងចេញថ្នាក់ជាតិ ដើម្បីបញ្ចប់ការសិក្សារបស់និស្សិតកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររងក្នុងវិស័យសុខាភិបាល (និស្សិត ១នាក់) | ៤% | ៩៥% | ១% |

ក២. ប្រាក់ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ ដែលមានចែងក្នុងឧបសម្ព័ន្ធ១ លើកលែងប្រភេទសេវាដែលបានកំណត់នៅក្នុងចំណុច ក១ ខាងលើ ត្រូវបានបែងចែក :

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃប្រាក់ចំណូលប្រមូលបាន
- ជូនក្រសួងសុខាភិបាល ចំនួន ៤៩% នៃប្រាក់ចំណូលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃប្រាក់ចំណូលប្រមូលបាន។

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត : ប្រាក់ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈដោយមន្ទីរសុខាភិបាលរាជធានី ខេត្ត ដែល មានចែងក្នុងឧបសម្ព័ន្ធ ២ ត្រូវបានបែងចែក :

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃប្រាក់ចំណូលប្រមូលបាន
- ជូនមន្ទីរសុខាភិបាលរាជធានី ខេត្ត ចំនួន ៤៩% នៃប្រាក់ចំណូលប្រមូលបាន
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃប្រាក់ចំណូលប្រមូលបាន

២. ចំពោះចំណូលប្រមូលបានពីការពិន័យជាប្រាក់

២.១ ចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងសុខាភិបាល

ចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ដែលមានចែងក្នុងឧបសម្ព័ន្ធ៣ ត្រូវបានបែងចែកដូចខាងក្រោម ÷

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃប្រាក់ពិន័យដែលប្រមូលបាន
- ជូនក្រសួងសុខាភិបាល ចំនួន ៤៩% នៃប្រាក់ពិន័យដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃប្រាក់ពិន័យដែលប្រមូលបាន
- ជូនមន្ទីរសុខាភិបាល ចំនួន ៤៩% នៃប្រាក់ពិន័យដែលប្រមូលបាន
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

២.២ ចំណូលពីការផ្តន្ទាទោសពិន័យជាប្រាក់ ដែលអនុវត្តតាមការសម្រេចរបស់សាលាជម្រះក្តី

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃប្រាក់ពិន័យដែលប្រមូលបាន
- ជូនក្រសួងសុខាភិបាល ចំនួន ២៥% នៃប្រាក់ពិន័យដែលប្រមូលបាន
- ជូនសាលាជម្រះក្តីពាក់ព័ន្ធ ចំនួន ២៤% នៃប្រាក់ពិន័យដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃប្រាក់ពិន័យដែលប្រមូលបាន
- ជូនមន្ទីរសុខាភិបាលរាជធានី ចំនួន ខេត្ត ២៥% នៃប្រាក់ពិន័យដែលប្រមូលបាន
- ជូនសាលាជម្រះក្តីពាក់ព័ន្ធ ចំនួន ២៤% នៃប្រាក់ពិន័យដែលប្រមូលបាន
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

**ប្រការ៥ .-**

រដ្ឋបាលកណ្តាលក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវគ្រោងចំណូលសរុប និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលក្រសួងសុខាភិបាល ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ទូទាត់ការចំណាយប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាលាជម្រះក្តីពាក់ព័ន្ធ។

មន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ទូទាត់ការចំណាយប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និង សាលាជម្រះក្តីពាក់ព័ន្ធ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលបានបុរេប្រទានពីចំណូលថវិកាជាតិ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចកិច្ចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាលក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលរាជធានី ខេត្តដែរ។

**ប្រការ៦ .-**

ការទូទាត់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ÷

ក. ផ្នែកចំណូល

ធ្វើសលាកប័ត្រចំណូលថវិកាជាតិនូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន និងសំណើសុំកត់ត្រាចំណូល ÷

- **ចំពោះរដ្ឋបាលកណ្តាលក្រសួងសុខាភិបាល :** បញ្ជូនសំណើ និងសលាកប័ត្រចំណូលថវិកាជាតិ មកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

- ចំពោះមន្ទីរក្រសួងសុខាភិបាល រាជធានី ខេត្ត ៖ បញ្ជូនសំណើ និងសលាកបត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកបត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកបត្រចំណូលថវិកាជាតិ។

ខ. ផ្នែកចំណាយ ៖ រដ្ឋបាលកណ្តាលក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវធ្វើសំណើសុំទូទាត់ចំណាយប្រាក់រង្វាន់លើកទឹកចិត្ត និងធ្វើអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះក្នុងសលាកបត្រចំណូលថវិកាជាតិ។

**ប្រការ៧ ._**

ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តដូចខាងក្រោម ÷

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសុខាភិបាល ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

គ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃសាលាជម្រះក្តីពាក់ព័ន្ធ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៨ ._**

ត្រូវបាននិរាករណ៍ប្រកាសរួមទាំងឡាយដូចខាងក្រោម ÷

- ប្រកាសរួមលេខ ៩៩៤ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសរួមលេខ ១៤៣៣ សហវ.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែប្រែតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៩៤ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៩ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី.០១... ខែ.ធ្នូ......... ឆ្នាំ២០១៦ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ  កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.០៣៦.៤..សហវ/ប្រក

# ប្រកាសរួម
## ស្តីពី
## ការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលាឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០, មាត្រា ៣៤, មាត្រា ៣៨, មាត្រា ៥០, មាត្រា ៦៦, មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រិសារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុវត្តការប្រមូលចំណូលពីការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្ទៃការ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .-**

ប្រភេទអគារដែលជាកម្មវត្ថុសម្រាប់ការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្ទៃការ រួមមាន÷

១- អគារលំនៅឋានដែលមានកម្ពស់ខ្ពស់ (លើសពី ១២ ជាន់ គិតទាំងជាន់ផ្ទាល់ដី)

២- អគារពាណិជ្ជកម្ម

៣- អគារពហុមុខងារ

៤- អគារបម្រើសេវាកម្មទេសចរណ៍

៥- អគារសណ្ឋាគារ។

**ប្រការ៣ .-**

ការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្ទៃការ ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីតម្លៃសេវា និងរយៈពេលអតិបរមានៃការផ្តល់សេវា ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចខាងក្រោម ÷

| ល.រ | ទំហំផ្ទៃក្រឡាកម្រាលសំណង់ ដែលលើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្ទៃការ គិតជាម៉ែត្រការ៉េ ($m^2$) | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) |
|---|---|---|---|
| ១ | ចាប់ពី ១០០ $m^2$ ចុះ | ២.០០០.០០០ | ៣០ថ្ងៃ |
| ២ | លើសពី ១០០ $m^2$ ដល់ ២០០ $m^2$ | ៤.០០០.០០០ | ៣០ថ្ងៃ |
| ៣ | លើសពី ២០០ $m^2$ ដល់ ៣០០ $m^2$ | ៦.០០០.០០០ | ៣០ថ្ងៃ |
| ៤ | លើសពី ៣០០ $m^2$ ដល់ ៤០០ $m^2$ | ៨.០០០.០០០ | ៣០ថ្ងៃ |
| ៥ | លើសពី ៤០០ $m^2$ ដល់ ៥០០ $m^2$ | ១០.០០០.០០០ | ៣០ថ្ងៃ |
| ៦ | លើសពី ៥០០ $m^2$ ដល់ ៦០០ $m^2$ | ១២.០០០.០០០ | ៣០ថ្ងៃ |
| ៧ | លើសពី ៦០០ $m^2$ ដល់ ៧០០ $m^2$ | ១៤.០០០.០០០ | ៣០ថ្ងៃ |
| ៨ | លើសពី ៧០០ $m^2$ ដល់ ៨០០ $m^2$ | ១៦.០០០.០០០ | ៣០ថ្ងៃ |
| ៩ | លើសពី ៨០០ $m^2$ ដល់ ៩០០ $m^2$ | ១៨.០០០.០០០ | ៣០ថ្ងៃ |
| ១០ | លើសពី ៩០០ $m^2$ ដល់ ១.០០០ $m^2$ | ២០.០០០.០០០ | ៣០ថ្ងៃ |
| ១១ | លើសពី ១.០០០ $m^2$ ដល់ ១.៥០០ $m^2$ | ៣០.០០០.០០០ | ៣០ថ្ងៃ |

| | | | |
|---|---|---|---|
| ១២ | លើសពី ១.៥០០ $m^2$ ដល់ ២.០០០ $m^2$ | ៤០.០០០.០០០ | ៣០ថ្ងៃ |
| ១៣ | លើសពី ២.០០០ $m^2$ ដល់ ២.៥០០ $m^2$ | ៥០.០០០.០០០ | ៣០ថ្ងៃ |
| ១៤ | លើសពី ២.៥០០ $m^2$ ដល់ ៣.០០០ $m^2$ | ៦០.០០០.០០០ | ៣០ថ្ងៃ |
| ១៥ | លើសពី ៣.០០០ $m^2$ ដល់ ៣.៥០០ $m^2$ | ៧០.០០០.០០០ | ៣០ថ្ងៃ |
| ១៦ | លើសពី ៣.៥០០ $m^2$ ដល់ ៤.០០០ $m^2$ | ៨០.០០០.០០០ | ៣០ថ្ងៃ |
| ១៧ | លើសពី ៤.០០០ $m^2$ ដល់ ៤.៥០០ $m^2$ | ៩០.០០០.០០០ | ៣០ថ្ងៃ |
| ១៨ | លើសពី ៤.៥០០ $m^2$ ដល់ ៥.០០០ $m^2$ | ១០០.០០០.០០០ | ៣០ថ្ងៃ |
| ១៩ | លើសពី ៥.០០០ $m^2$ ដល់ ៥.៥០០ $m^2$ | ១១០.០០០.០០០ | ៣០ថ្ងៃ |
| ២០ | លើសពី ៥.៥០០ $m^2$ ដល់ ៦.០០០ $m^2$ | ១២០.០០០.០០០ | ៣០ថ្ងៃ |
| ២១ | លើសពី ៦.០០០ $m^2$ ដល់ ៦.៥០០ $m^2$ | ១៣០.០០០.០០០ | ៣០ថ្ងៃ |
| ២២ | លើសពី ៦.៥០០ $m^2$ ដល់ ៧.០០០ $m^2$ | ១៤០.០០០.០០០ | ៣០ថ្ងៃ |
| ២៣ | លើសពី ៧.០០០ $m^2$ ដល់ ៧.៥០០ $m^2$ | ១៥០.០០០.០០០ | ៣០ថ្ងៃ |
| ២៤ | លើសពី ៧.៥០០ $m^2$ ដល់ ៨.០០០ $m^2$ | ១៦០.០០០.០០០ | ៣០ថ្ងៃ |
| ២៥ | លើសពី ៨.០០០ $m^2$ ដល់ ៨.៥០០ $m^2$ | ១៧០.០០០.០០០ | ៣០ថ្ងៃ |
| ២៦ | លើសពី ៨.៥០០ $m^2$ ដល់ ៩.០០០ $m^2$ | ១៨០.០០០.០០០ | ៣០ថ្ងៃ |
| ២៧ | លើសពី ៩.០០០ $m^2$ ដល់ ៩.៥០០ $m^2$ | ១៩០.០០០.០០០ | ៣០ថ្ងៃ |
| ២៨ | លើសពី ៩.៥០០ $m^2$ ដល់ ១០.០០០ $m^2$ | ២០០.០០០.០០០ | ៣០ថ្ងៃ |
| ២៩ | លើសពី ១០.០០០ $m^2$ ដល់ ១៥.០០០ $m^2$ | ៣០០.០០០.០០០ | ៣០ថ្ងៃ |
| ៣០ | លើសពី ១៥.០០០ $m^2$ ដល់ ២០.០០០ $m^2$ | ៤០០.០០០.០០០ | ៣០ថ្ងៃ |
| ៣១ | លើសពី ២០.០០០ $m^2$ | ៥០០.០០០.០០០ | ៣០ថ្ងៃ |

**ប្រការ៤ .-**

នីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៥ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសរួម និងនីតិវិធី ព្រមទាំងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ មានការយឺតយ៉ាវក្នុងការផ្តល់សេវាសាធារណៈជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់លេខទូរស័ព្ទ សារអេឡិចត្រូនិក ប្រអប់សំបុត្រ និងផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬ អង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

**ប្រការ៦ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ៧ .-**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការប្រមូលចំណូលពីការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលដែលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៩ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ១០ .-**

កម្រងសេវាសាធារណៈដូចមានចែងក្នុងប្រការ៣ នៃប្រកាសរួមនេះ អាចកែប្រែបានតាមការចាំបាច់តាមរយៈប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០១៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៧៦ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការតែងតាំងគ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស របស់អគ្គនាយកដ្ឋានរតនាគារជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/១៣៩៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៥៤២ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តមាតិកាគណនីគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្ដីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០០៥ សហវ.ប្រក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ ស្ដីពីគោលការណ៍និងនីតិវិធីផ្ទៃក្នុងសម្រាប់ការអនុវត្តថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១:** ត្រូវបានតែងតាំងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានរតនាគារជាតិ ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. លោកស្រី | **ឯក តារារី** | ប្រធានការិយាល័យបុគ្គលិក | ជាភ្នាក់ងារបើកផ្ដល់ |
| ២. លោក | **ម៉ក់ សុភាព** | អនុប្រធានការិយាល័យបុគ្គលិក | ជាភ្នាក់ងារបើកផ្ដល់ជំនួស |
| ៣. លោក | **អ៊ុំ ចាន់ណារិន** | អនុប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ | ជាភ្នាក់ងារបើកផ្ដល់ជំនួស |

**ប្រការ២:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣:** នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦

ណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៤១ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតនិងតែងតាំងក្រុមលទ្ធកម្ម របស់អគ្គនាយកដ្ឋានរតនាគារជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/១៣៩៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នរ/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ១៥៤២ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ១:** ត្រូវបានបង្កើត និងតែងតាំងក្រុមលទ្ធកម្មរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ខេង ម៉ិនឥន្ទ្រាវុធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ | ប្រធាន |
| ២. លោក | **អ៊ា សូទី** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក | អនុប្រធាន |
| ៣. លោក | **ស៊ិន ច័ន្ទភក្កដា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក | សមាជិក |
| ៤. លោក | **ពុន ហាខៀន** | អនុប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៥. លោកស្រី | **ហ្វួន អ៊ាំដែត** | អនុប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ២:** ប្រគល់សិទ្ធិអនុវត្តជូនក្រុមលទ្ធកម្មរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីអនុវត្តកិច្ចលទ្ធកម្មក្នុងក្របខណ្ឌថវិកាដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្ទេរសិទ្ធិតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ៣:** ក្រុមលទ្ធកម្មមានភារកិច្ចជាសារវន្តដូចខាងក្រោម÷

- រៀបចំសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវ និងអនុវត្តកិច្ចលទ្ធកម្មឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម ដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កំណត់បុរេលក្ខណៈសម្បត្តិចំពោះលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- រៀបចំពិនិត្យ និងសម្រេចលើឯកសារដេញថ្លៃដែលស្ថិតនៅក្នុងសិទ្ធិសម្រេចរបស់ខ្លួន ឬបញ្ជូនឯកសារដេញថ្លៃទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងផ្តល់ទិដ្ឋាការចំពោះកិច្ចលទ្ធកម្មដែលលើសសិទ្ធសម្រេចរបស់ខ្លួន
- រៀបចំ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីការដេញថ្លៃនិងការលក់ឬផ្តល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងការដេញថ្លៃ
- ទទួលសំណើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃទាំងអស់ ក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ
- ប្រជុំបើកសំណើដេញថ្លៃ
- រៀបចំរបាយការណ៍ ឬកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ
- ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា
- ត្រួតពិនិត្យនិងវាយតម្លៃលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខ
- រៀបចំនិងផ្ញើលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ នឹងចម្លងជូនអ្នកដេញថ្លៃចាញ់
- រៀបចំការផ្សាយលទ្ធផលនៃការដេញថ្លៃ
- រៀបចំកិច្ចសន្យាស្របតាមបទដ្ឋានឯកសារកិច្ចសន្យា ដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដានការអនុវត្តកិច្ចសន្យា
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ។

**ប្រការ៤:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥:** នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៦

ហត្ថលេខា. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ